## តារាងចំណុចស្ដីអំពីលទ្ធភាពស្ដាប់និងការនិយាយដែលត្រូវពិនិត្យរបស់ ...

### ចាប់ពីកើតដល់៣ខែ

- ☐ មិនផ្អើលនឹងសម្លេងឬសម្លេងនិយាយដែលខ្លួនធ្លាប់ស្គាល់
- ☐ ភ្ញាក់ឬលោតនៅពេលមានសម្លេងកើតឡើងភ្លាមៗ

### ៣ទៅ៦ខែ

- ☐ ងាកឬក្រឡេកភ្នែកឆ្ពោះទៅសម្លេងដែលគួរឲ្យចាប់អារម្មណ៍
- ☐ ឃើញហាក់ដូចជាចេះស្ដាប់
- ☐ ងាយភ្ញាក់ដឹងខ្លួនដោយសារសម្លេង
- ☐ ចាប់ផ្ដើមធ្វើសម្លេងបែបសម្លេងនិយាយ

### ៦ទៅ១២ខែ

- ☐ យល់ពាក្យងាយៗដូចជា "ទេ" និង "លាហើយ"
- ☐ ចាប់ផ្ដើមថាតាមសម្លេងពាក្យ
- ☐ ងាកទៅរកសម្លេងដែលឮតិចៗ

### ១២ទៅ១៨ខែ

- ☐ ឃើញដូចជាយល់ពាក្យកាន់តែច្រើនឡើងរៀងរាល់សប្ដាហ៍
- ☐ ពេលគេសួរ ចង្អុលទៅមនុស្ស ផ្នែកដងខ្លួន ឬតុក្កតាលេង
- ☐ ធ្វើតាមពាក្យបង្គាប់ដែលងាយៗ ដូចជា "អង្គុយចុះ"
- ☐ និយាយពីរឬបីពាក្យពិតៗ ដូចជា "បាល់" "ឆ្កែឡាន"

បើអ្នកមានការបារម្ភអំពីលទ្ធភាពស្ដាប់របស់ទារកអ្នក សូមទាក់ទងទៅវេជ្ជបណ្ឌិតរបស់ទារកអ្នក ឬមួយបុគ្គលិកនៅគ្លីនិកក្នុងតំបន់របស់អ្នក។




កម្មវិធីត្រចៀកមានសុខភាពល្អរបស់សុខាភិបាលរដ្ឋឃ្វីនស៍លែនមានគោលដៅរកឲ្យដឹងទារកទាំងឡាយណាដែលបាត់បង់លទ្ធភាពស្ដាប់ជាអចិន្ត្រៃយ៍។ កម្មវិធីនេះឥតគិតថ្លៃទេសម្រាប់ទារកមានសិទ្ធិមេឌិឃែរកើតនៅរដ្ឋឃ្វីនស៍លែនទាំងអស់។

**www.health.qld.gov.au/healthyhearing**

Queensland Government

Reviewed 2018

Language: Khmer

# ការធ្វើតេស្តត្រចៀកសាមញ្ញរបស់ទារកអ្នក




Queensland Government

# ការធ្វើតេស្តត្រចៀកសាមញ្ញរបស់ទារកអ្នក

ត្រចៀកមានសុខភាពល្អមានសារៈសំខាន់បំផុតសម្រាប់ការលូតលាស់ផ្នែកនិយាយនិងភាសារបស់កូនអ្នកចាប់តាំងពីខែដំបូងបំផុតនៃជីវិត។ ទារកប្រមាណ១ឬ២ក្នុងចំណោម១០០០នាក់នឹងមានភាពបាត់បង់លទ្ធភាពស្តាប់ខ្ពស់។

បើគេមិនរកឲ្យឃើញការបាត់បង់លទ្ធភាពស្តាប់ឲ្យឆាប់ទេ វាអាចប៉ះពាល់ដល់ការលូតលាស់ផ្នែកនិយាយនិងភាសារបស់កូនអ្នក ហើយនិងការរៀនសូត្រនៅសាលាទៅអនាគត។

## ការណាត់ធ្វើតេស្តត្រចៀកសាមញ្ញសម្រាប់

..............................

ថ្ងៃទី ....................

ម៉ោង ....................

កន្លែង ....................

## ផ្នែកនៃការពិនិត្យសុខភាពរបស់ទារក

កម្មវិធីត្រចៀកមានសុខភាពល្អមានគោលបំណងរកឲ្យឃើញទារកដែលកើតមកមានការបាត់បង់លទ្ធភាពស្តាប់ជាអចិន្ត្រៃយ៍។ កម្មវិធីនេះឥតមានគិតថ្លៃសម្រាប់ទារកទាំងអស់កើតនៅរដ្ឋឃ្វីនស៍លែនហើយដែលមានសិទ្ធិមេឌិឃែរ។

បន្ទាប់ពីកើតមក ទារកអ្នកនឹងត្រូវបានផ្តល់ការពិនិត្យសុខភាពមួយចំនួន។ ក្នុងចំណោមនោះមានការធ្វើតេស្តត្រចៀកសាមញ្ញ។ ការធ្វើតេស្តនេះគួរធ្វើឡើងយ៉ាងឆាប់បំផុតបន្ទាប់ពីទារកកើត។ ប្រសិនបើមិនបានធ្វើតេស្តនេះមុនពេលអ្នកចេញពីមន្ទីរពេទ្យទេ ទារកអ្នកនៅតែអាចទៅធ្វើតេស្តសាមញ្ញមិនយូរក្រោយពីបានចេញទៅផ្ទះក្នុងនាមជាអ្នកជម្ងឺទៅពីក្រៅមន្ទីរពេទ្យ។

## តើគេធ្វើតេស្តសាមញ្ញរបៀបណា?

ការធ្វើតេស្តត្រចៀកសាមញ្ញមិនធ្វើឲ្យទារកឈឺទេ។ គិលានុប្បដ្ឋាកឬអ្នកដែលមានការហាត់រៀនខាងការធ្វើតេស្តត្រចៀកសាមញ្ញនឹងធ្វើតេស្តត្រចៀកសាមញ្ញទារកអ្នកនៅពេលទារកនៅស្ងាត់ស្ងៀមឬគេងលក់។ គេនឹងដាក់បន្ទះ៤-៥ លើក្បាលទារក ហើយឧបករណ៍ស្តាប់ត្រចៀកទន់ដាក់លើត្រចៀកនិមួយៗ។ គេចាក់សម្លេងញស្រាលៗមួយសំណុំបញ្ចូលទៅក្នុងត្រចៀកទារក។ បន្ទះទាំងនោះនឹងថតប្រតិកម្មទារកអ្នកតបទៅសម្លេងទាំងនោះ។

## តើខ្ញុំនឹងដឹងលទ្ធផលនៅពេលណា?

លទ្ធផលនៃការធ្វើតេស្តសាមញ្ញនឹងត្រូវដឹងភ្លាមហើយនឹងត្រូវកត់ទុកក្នុងបញ្ជីសុខភាពរបស់ទារកអ្នក។ អ្នកធ្វើតេស្តសាមញ្ញនឹងពិភាក្សាអំពីលទ្ធផលជាមួយអ្នក។ចូរសួរសំនួរប្រសិនបើមានអ្វីដែលអ្នកមិនច្បាស់។

## តើការធ្វើតេស្តសាមញ្ញផ្តល់ព័ត៌មានអ្វីខ្លះដល់យើង?

សម្រាប់ត្រចៀកនិមួយៗ ការធ្វើតេស្តសាមញ្ញនឹងប្រាប់យើងថាលទ្ធផល ‘ជាប់’ ឬ ‘បញ្ជូនឈ្មោះ’។ ការធ្វើតេស្តសាមញ្ញមិនផ្តល់ឲ្យយើងនូវព័ត៌មានលំអិតឡើយ។

## តើលទ្ធផលថា ‘ជាប់’មានន័យដូចម្តេច?

លទ្ធផលថា ‘ជាប់’របស់ត្រចៀកទាំងសងខាងបញ្ជាក់ថាទារកអ្នកមិនទំនងមានបញ្ហាបាត់បង់លទ្ធភាពស្តាប់ដែលប៉ះពាល់ដល់ការលូតលាស់ក្នុងការនិយាយនិងភាសានោះទេ។

មានទារកមួយចំនួនតូចអាចជាប់តេស្តសាមញ្ញ ប៉ុន្តែមានកត្តាហានិភ័យសម្រាប់ភាពបាត់បង់លទ្ធភាពស្តាប់មួយចំនួនដែលស៊ីពេលយូរបានលេចឡើង។ ប្រសិនបើករណីនេះជាករណីរបស់អ្នក ទារកអ្នកនឹងត្រូវបានឲ្យទៅជួបអ្នកផ្នែកសោតវិទ្យាពេលណាមួយមុននឹងកុមារនោះបានអាយុ១ឆ្នាំ។ពេលវេលាសម្រាប់ការធ្វើតេស្តនេះអាស្រ័យលើសេចក្តីត្រូវការជាក់លាក់របស់កូនអ្នក។ទោះបីមានទារកដែលមានកត្តាហានិភ័យទាំងនេះមានចំនួនតិចតួចប៉ុណ្ណោះដែលនឹងកើត ភាពបាត់បង់លទ្ធភាពស្តាប់ វាជាការសំខាន់ដែលយើងធានាឲ្យទារកនោះទទួលបានការធ្វើតេស្តរបស់ខ្លួន។

ចូរចាំថា លទ្ធភាពស្តាប់របស់ទារកនិងកុមារគ្រប់រូប យូរទៅអាចដូរ។ នៅពេលណាក៏ដោយបើអ្នកមានការបារម្ភអំពីលទ្ធភាពស្តាប់របស់កូនអ្នក ចូរទាក់ទងគ្រូពេទ្យរបស់អ្នកឬបុគ្គលិកនៅគ្លីនិកនៅមូលដ្ឋានអ្នក។ ការធ្វើតេស្តត្រចៀកទារកនិងកុមារអាចធ្វើនៅអាយុប៉ុណ្ណាក៏បាន។

## តើលទ្ធផលថា ‘បញ្ជូនឈ្មោះ’ មានន័យដូចម្តេច?

លទ្ធផលថា ‘បញ្ជូនឈ្មោះ’ របស់ការធ្វើតេស្តសាមញ្ញអាចបណ្តាលមកពីកត្តាមួយចំនួនៈ

- ទារកអ្នកនៅមិនស្ងៀមក្នុងពេលធ្វើតេស្តសាមញ្ញ
- អាចមានសម្លេងរំខានបរិស្ថានជុំវិញក្នុងពេលធ្វើតេស្តសាមញ្ញ
- ទារកអ្នកអាចមានទឹកឬមានអ្វីធ្វើឲ្យស្ទះបណ្តោះអាសន្នក្នុងត្រចៀកពេលធ្វើតេស្តសាមញ្ញ។
- ទារកមួយចំនួនតូចអាចមានភាពបាត់បង់លទ្ធភាពស្តាប់បណ្តោះអាសន្នឬជាអចិន្ត្រៃយ៍។ កម្រិតនៃភាពបាត់បង់អាចមានពីតិចតួចរហូតដល់ខ្ពស់។

បើការធ្វើតេស្តត្រចៀកសាមញ្ញលើកទី១របស់ទារកអ្នកបានលទ្ធផល ‘បញ្ជូនឈ្មោះ’ សម្រាប់ត្រចៀក១ឬទាំង២ ការធ្វើតេស្តសាមញ្ញលើកទី២នឹងត្រូវមានធ្វើ។

ប្រសិនបើការធ្វើតេស្តត្រចៀកសាមញ្ញលើកទី១របស់ទារកអ្នកបានលទ្ធផល ‘បញ្ជូនឈ្មោះ’ សម្រាប់ត្រចៀក១ឬទាំង២ អ្នកនឹងត្រូវបានបញ្ជូនឈ្មោះទៅជួបអ្នកផ្នែកសោតវិទ្យា ហើយនិងសេវាកម្មគាំទ្រគ្រួសារផង។ អ្នកនឹងត្រូវបានផ្តល់ជូនបន្ថែមនូវកូនសៀវភៅពន្យល់អំពីរឿងនេះជាលំអិតថែមទៀត។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមទៀតនៅទីណា?

បើអ្នកចង់បានព័ត៌មានបន្ថែមអំពីការធ្វើតេស្តត្រចៀកសាមញ្ញរបស់ទារកអ្នក ចូរទាក់ទងជាមួយមន្ទីពេទ្យនៅមូលដ្ឋានរបស់អ្នក គ្រូពេទ្យរបស់ទារករអ្នក ឬក៏បុគ្គលិកគ្លីនិកនៅមូលដ្ឋានអ្នក។






